ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ :.....ក.ប/ន.ស

សារលិខិតជូនពរ

គោរពជូន
ឯកឧត្តមសាស្ត្រាចារ្យ ឈាង វ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល
ជាទីគោរពរាប់អាន!

ក្នុងឱកាសខួបកំណើតដ៏ជ័យមង្គលដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៦នេះ ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមប្រសិទ្ធពរជ័យជូនចំពោះ **ឯកឧត្តមសាស្ត្រាចារ្យ ឈាង វ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល** ទទួលបាននូវបញ្ញាញាណក្លឹថ្លាវាងវៃ កម្លាំងពលំមាំមួន ជន្មាយុយឺនយូរ និងសម្រេចជោគជ័យដ៏ត្រចះត្រចង់ក្នុងបេសកកម្មរៀបចំគោលនយោបាយសំខាន់ៗជាច្រើន ជាពិសេស ក្នុងបេសកកម្មដឹកនាំគ្រប់គ្រងវិស័យសុខាភិបាលនៅកម្ពុជា និងការបំពេញតួនាទីភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន សម្រេចបានជោគជ័យ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងកិច្ចការពារសុខសន្តិភាព ការស្តារ កសាង និងអភិវឌ្ឍជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យប្រកបដោយឆន្ទៈ និងមនសិការកក្តីភាពយ៉ាងមោះមុតជូនជាតិមាតុភូមិ និងប្រជាជន។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្វសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ជូនចំពោះ **ឯកឧត្តមសាស្ត្រាចារ្យ** និង**លោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមសាស្ត្រាចារ្យ ឈាង វ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល** ទទួលនូវសេចក្តីគោរពរាប់អានពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៦

តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ
ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
រដ្ឋមន្ត្រី

ហេង សួរ